ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៤ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ សាធារណៈ និងឯកជន សម្រាប់ឆ្នាំសិក្សា២០២២-២០២៣

ដើម្បីឱ្យការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសម្រាប់ឆ្នាំសិក្សា ២០២២-២០២៣ ស្របតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

**១.ប្រតិទិននៃការប្រឡង**

**១.១-ការប្រឡងឆមាសលើកទី១**

- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ ទី១១ : ពីថ្ងៃទី០៥ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣
- សម្រាប់ថ្នាក់ទី៩ : ពីថ្ងៃទី២៩ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣
- សម្រាប់ថ្នាក់ទី១២ : ពីថ្ងៃទី២២ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣
- បូកសរុបឆមាសលើកទី១ : ពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣
- វិស្សមកាលតូច : ពីថ្ងៃទី០៦ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣
- វិស្សមកាលធំ : ពីថ្ងៃទី២០ ខែមេសា ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣

**១.២-ការប្រឡងឆមាសលើកទី២**

- សម្រាប់ថ្នាក់ទី៩ : ពីថ្ងៃទី១១ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣
- សម្រាប់ថ្នាក់ទី១២ : ពីថ្ងៃទី២១ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣
- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ ទី១១ : ពីថ្ងៃទី១៦ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣

**១.៣-ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា សម្រាប់ថ្នាក់ទី៩ និងទី១២**

- សម័យប្រឡង៖ ១២ មិថុនា ២០២៣ នៅមណ្ឌល៖ **វិទ្យាល័យ នេត យ៉ង់ ខេត្តបាត់ដំបង**
- កាលបរិច្ឆេទប្រារព្ធពិធីបិទការប្រឡង និងចែករង្វាន់ដល់ជ័យលាភី៖ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣

**១.៤-ការប្រឡងសញ្ញាបត្រមធ្យមសិក្សា**

- បឋមភូមិ : ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣
- ប្រកាសលទ្ធផល : ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣
- ទុតិយភូមិ : ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣
- ប្រកាសលទ្ធផល : ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៣៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ២.ការប្រឡងឆមាសសម្រាប់ថ្នាក់ទី៩

ចំពោះសិស្សថ្នាក់ទី៩ មធ្យមភាគពិន្ទុប្រចាំឆ្នាំ ត្រូវគិតពិន្ទុខែជាមួយដែរ។

### ២.១-រយៈពេលប្រឡង និងរបបពិន្ទុ      ពិន្ទុសរុប=៤២០

| ល.រ | វិញ្ញាសា | រយៈពេល (នាទី) | ពិន្ទុអតិបរមា |
|---|---|---|---|
| ១ | តែងសេចក្តី | ៩០ | ៦០ |
| ២ | ការសរសេរតាមអាន | ៦០ | ៤០ |
| ៣ | គណិតវិទ្យា | ១២០ | ១០០ |
| ៤ | រូបវិទ្យា | ៤៥ | ៣៥ |
| ៥ | គីមីវិទ្យា | ៣០ | ២៥ |
| ៦ | ជីវវិទ្យា | ៤៥ | ៣៥ |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | ៣០ | ២៥ |
| ៨ | សីលធម៌-ពលរដ្ឋវិជ្ជា | ៤៥ | ៣៥ |
| ៩ | ភូមិវិទ្យា | ៤០ | ៣២ |
| ១០ | ប្រវត្តិវិទ្យា | ៤០ | ៣៣ |
| ១១ | ភាសាបរទេស | ៤៥ | ៥០ |

*ចំពោះមុខវិជ្ជាភាសាបរទេសពិន្ទុត្រូវយកមកបូកគឺជាផលសងនៃពិន្ទុដែលសិស្សធ្វើបានដកនឹង២៥។ ពិន្ទុនេះបូកជាមួយពិន្ទុមុខវិជ្ជាដទៃរួចហើយ ទើបគណនារកមធ្យមភាគពិន្ទុប្រឡងឆមាសជាក្រោយ។

### ២.២-មធ្យមភាគពិន្ទុប្រចាំឆ្នាំ

- មធ្យមភាគពិន្ទុប្រចាំខែ=ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i=៨.៤(គិត៥០ពិន្ទុ) និងយកពិន្ទុតាមមុខវិជ្ជាដូចប្រឡងឆមាសដែរ)
- មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុខែក្នុងឆមាសចែកនឹងចំនួនខែក្នុងឆមាស(គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រឡងឆមាស=ផលបូកពិន្ទុប្រឡងឆមាសគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍i=៨.៤(គិត ៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆមាស= $\frac{\text{មធ្យមភាគពិន្ទុប្រឡងឆមាស+មធ្យមភាគពិន្ទុខែប្រចាំឆមាស}}{\text{២}}$ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆ្នាំ= $\frac{\text{មធ្យមភាគពិន្ទុប្រចាំឆមាសទី១+មធ្យមភាគពិន្ទុប្រចាំឆមាសទី២}}{\text{២}}$ (គិត៥០ពិន្ទុ)

**ឧទាហរណ៍** : ការគណនាមធ្យមភាគពិន្ទុប្រចាំឆ្នាំរបស់សិស្ស « ក »

| វិញ្ញាសា | ឆមាសទី១ | ឆមាសទី២ |
|---|---|---|
| គណិតវិទ្យា | ៧០ | ៨២ |
| តែងសេចក្តី | ៣២ | ៣១ |
| ការសរសេរតាមអាន | ៣៥ | ២៨ |
| រូបវិទ្យា | ២៤ | ២០ |
| គីមីវិទ្យា | ២០ | ២៤ |
| ជីវវិទ្យា | ១៧ | ២០ |
| ផែនដី និងបរិស្ថានវិទ្យា | ១៥ | ២២ |
| សីលធម៌-ពលរដ្ឋវិជ្ជា | ២៥ | ២១ |
| ភូមិវិទ្យា | ២៣ | ២៥ |

| | | |
|---|---|---|
| ប្រវត្តិវិទ្យា | ២៤ | ២៣ |
| ភាសាបរទេស | ៣១ - ២៥ = ៦ | ៣៣ -២៥ = ៨ |
| ផលបូកពិន្ទុប្រឡងឆមាស | ២៩១ | ៣០៤ |
| មធ្យមភាគពិន្ទុប្រឡងឆមាស | ៣៤.៦៤ | ៣៦.១៩ |
| មធ្យមភាគពិន្ទុខែប្រចាំឆមាស | ៣៥.២៤ | ៣៧.២៣ |
| មធ្យមភាគពិន្ទុប្រចាំឆមាស | ៣៤.៩៤ | ៣៦.៧១ |

មធ្យមភាគពិន្ទុប្រចាំឆ្នាំ= $\frac{៣៤.៩៤+៣៦.៧១}{២}$ = ៣៥.៨២

### ៣. ការប្រឡងឆមាសសម្រាប់ថ្នាក់ទី១២

ចំពោះសិស្សថ្នាក់ទី១២ មធ្យមភាគពិន្ទុប្រចាំឆ្នាំ ត្រូវគិតពិន្ទុខែជាមួយដែរ។

**៣.១–រយៈពេលប្រឡង និងរបបពិន្ទុ** ពិន្ទុសរុប =៦២៥

| ល.រ | វិញ្ញាសា | ថ្នាក់៖ វិទ្យាសាស្ត្រ | | ថ្នាក់៖ វិទ្យាសាស្ត្រសង្គម | |
|---|---|---|---|---|---|
| | | រយៈពេល(នាទី) | ពិន្ទុអតិបរមា | រយៈពេល(នាទី) | ពិន្ទុអតិបរមា |
| ១ | អក្សរសាស្ត្រខ្មែរ | ៩០ | ៧៥ | ១៥០ | ១២៥ |
| ២ | គណិតវិទ្យា | ១៥០ | ១២៥ | ៩០ | ៧៥ |
| ៣ | រូបវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |
| ៤ | គីមីវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |
| ៥ | ជីវវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |
| ៦ | ផែនដី និងបរិស្ថានវិទ្យា | ៦០ | ៥០ | ៦០ | ៥០ |
| ៧ | សីលធម៌-ពលរដ្ឋវិជ្ជា | ៦០ | ៥០ | ៩០ | ៧៥ |
| ៨ | ភូមិវិទ្យា | ៦០ | ៥០ | ៩០ | ៧៥ |
| ៩ | ប្រវត្តិវិទ្យា | ៦០ | ៥០ | ៩០ | ៧៥ |
| ១០ | ភាសាបរទេស | ៦០ | ៥០ | ៦០ | ៥០ |

* ចំពោះមុខវិជ្ជាភាសាបរទេសពិន្ទុត្រូវយកមកបូកគឺជាផលសងនៃពិន្ទុដែលសិស្សធ្វើបានដកនឹង២៥។ ពិន្ទុនេះបូកជាមួយពិន្ទុមុខវិជ្ជាដទៃរួចហើយ ទើបគណនារកមធ្យមភាគពិន្ទុឆមាសជាក្រោយ។

**៣.២–មធ្យមភាគពិន្ទុប្រចាំឆ្នាំ**

- មធ្យមភាគពិន្ទុប្រចាំខែ=ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i=១២.៥ (គិត៥០ពិន្ទុ និងយកពិន្ទុតាម មុខវិជ្ជាដូចប្រឡងឆមាសដែរ)
- មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុខែក្នុងឆមាសចែកនឹងចំនួនខែក្នុងឆមាស(គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រឡងឆមាស=ផលបូកពិន្ទុប្រឡងឆមាសគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i= ១២.៥ (គិត ៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆមាស= $\frac{\text{មធ្យមភាគពិន្ទុប្រឡងឆមាស+មធ្យមភាគពិន្ទុខែប្រចាំឆមាស}}{២}$ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆ្នាំ= $\frac{\text{មធ្យមភាគពិន្ទុប្រចាំឆមាសទី១+មធ្យមភាគពិន្ទុប្រចាំឆមាសទី២}}{២}$ (គិត៥០ពិន្ទុ)

**ឧទាហរណ៍៖** ការគណនាមធ្យមភាគពិន្ទុប្រចាំឆ្នាំរបស់សិស្ស « ខ » រៀនថ្នាក់វិទ្យាសាស្ត្រ

| វិញ្ញាសា | ឆមាសទី១ | ឆមាសទី២ |
|---|---|---|
| អក្សរសាស្ត្រខ្មែរ | ៧០ | ៦០ |

| | | |
|---|---|---|
| គណិតវិទ្យា | ៩០ | ៧០ |
| រូបវិទ្យា | ៦០ | ៥៥ |
| គីមីវិទ្យា | ៣០ | ២០ |
| ជីវវិទ្យា | ២០ | ៣០ |
| សីលធម៌-ពលរដ្ឋវិជ្ជា | ៣០ | ២៥ |
| ប្រវត្តិវិទ្យា | ២៥ | ២០ |
| ភូមិវិទ្យា | ២៥ | ២០ |
| ផែនដី និងបរិស្ថានវិទ្យា | ២០ | ១៥ |
| ភាសាបរទេស | ៤២-២៥ = ១៧ | ៤០-២៥ = ១៥ |
| ផលបូកពិន្ទុប្រឡងឆមាស | ៣៨៧ | ៣៣០ |
| មធ្យមភាគពិន្ទុប្រឡងឆមាស | ៣០.៩៦ | ២៦.៤០ |
| មធ្យមភាគពិន្ទុខែប្រចាំឆមាស | ៣៥.២៤ | ៣៧.២៣ |
| មធ្យមភាគពិន្ទុប្រចាំឆមាស | ៣៣.១០ | ៣១.៨១ |

មធ្យមភាគពិន្ទុប្រចាំឆ្នាំ $= \frac{៣៣.១០+៣១.៨១}{២} =$ ៣២.៤៥

**ឧទាហរណ៍៖** ការគណនាមធ្យមភាគពិន្ទុប្រចាំឆ្នាំរបស់សិស្ស « គ » រៀនថ្នាក់វិទ្យាសាស្ត្រសង្គម

| **មុខវិជ្ជា** | **ឆមាសទី១** | **ឆមាសទី២** |
|---|---|---|
| អក្សរសាស្ត្រខ្មែរ | ៩០ | ៧០ |
| គណិតវិទ្យា | ៧០ | ៦៥ |
| រូបវិទ្យា | ៤៥ | ៤០ |
| គីមីវិទ្យា | ៣០ | ៣៥ |
| ជីវវិទ្យា | ៤០ | ៤០ |
| សីលធម៌-ពលរដ្ឋវិជ្ជា | ៥០ | ៧០ |
| ប្រវត្តិវិទ្យា | ៧០ | ៦៥ |
| ភូមិវិទ្យា | ៦០ | ៧០ |
| ផែនដី និងបរិស្ថានវិទ្យា | ៤០ | ៤០ |
| ភាសាបរទេស | ៤២-២៥ = ១៧ | ៤០-២៥ = ១៥ |
| ផលបូកពិន្ទុប្រឡងឆមាស | ៥១២ | ៥១០ |
| មធ្យមភាគពិន្ទុប្រឡងឆមាស | ៤០.៩៦ | ៤០.៨០ |
| មធ្យមភាគពិន្ទុខែប្រចាំឆមាស | ៣៥.២៤ | ៣៧.២៣ |
| មធ្យមភាគពិន្ទុប្រចាំឆមាស | ៣៨.១០ | ៣៩.០១ |

មធ្យមភាគពិន្ទុប្រចាំឆ្នាំ $= \frac{៣៨.១០+៣៩.០១}{២} =$ ៣៨.៥៥

## ៤. ការប្រឡងឆមាសសម្រាប់ថ្នាក់ទី៧ និងទី៨

ចំពោះសិស្សថ្នាក់ទី៧ និងទី៨ មធ្យមភាគពិន្ទុប្រចាំឆ្នាំ ត្រូវគិតពិន្ទុខែជាមួយផង។ ការប្រឡងឆមាសគឺត្រូវធ្វើគ្រប់មុខវិជ្ជាដែលមានចែងក្នុងកម្មវិធីសិក្សា។

### ៤.១- រយៈពេលប្រឡង និងរបបពិន្ទុ ពិន្ទុសរុប=៧៥០

| ល.រ | មុខវិជ្ជា | រយៈពេល (នាទី) | ពិន្ទុអតិបរមា |
|---|---|---|---|
| ១ | តែងសេចក្តី | ៩០ | ៦០ |
| ២ | ការសរសេរតាមអាន | ៦០ | ៤០ |
| ៣ | គណិតវិទ្យា | ១២០ | ១០០ |
| ៤ | រូបវិទ្យា | ៥០ | ៥០ |
| ៥ | គីមីវិទ្យា | ៥០ | ៥០ |
| ៦ | ជីវវិទ្យា | ៥០ | ៥០ |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | ៥០ | ៥០ |
| ៨ | សីលធម៌-ពលរដ្ឋវិជ្ជា | ៥០ | ៥០ |
| ៩ | ភូមិវិទ្យា | ៥០ | ៥០ |
| ១០ | ប្រវត្តិវិទ្យា | ៥០ | ៥០ |
| ១១ | ភាសាបរទេស | ៥០ | ៥០ |
| ១២ | គេហវិទ្យា | ៥០ | ៥០ |
| ១៣ | អប់រំកាយ កីឡា និងសុខភាព | ៥០ | ៥០ |
| ១៤ | បំណិនជីវិតតាមមូលដ្ឋាន (សិល្បៈ កសិកម្ម ពេងជាង...) | ៥០ | ៥០ |

### ៤.២-មធ្យមភាគពិន្ទុប្រចាំឆ្នាំ

- មធ្យមភាគពិន្ទុប្រចាំខែ = ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i = ១៥ (គិត ៥០ពិន្ទុ)
- មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុខែក្នុងឆមាសចែកនឹងចំនួនខែក្នុងឆមាស (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រឡងឆមាស=ផលបូកពិន្ទុប្រឡងឆមាសគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i=១៥ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆមាស= $\frac{\text{មធ្យមភាគពិន្ទុប្រឡងឆមាស+មធ្យមភាគពិន្ទុខែប្រចាំឆមាស}}{២}$ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆ្នាំ= $\frac{\text{មធ្យមភាគពិន្ទុប្រចាំឆមាសទី១+មធ្យមភាគពិន្ទុប្រចាំឆមាសទី២)}}{២}$ (គិត៥០ពិន្ទុ)

**ឧទាហរណ៍** : ការគណនាមធ្យមភាគពិន្ទុប្រចាំឆ្នាំរបស់សិស្ស « ឃ »

| មុខវិជ្ជា | ឆមាសទី១ | ឆមាសទី២ |
|---|---|---|
| តែងសេចក្តី | ៣៤ | ២៩ |
| ការសរសេរតាមអាន | ៣៨ | ៤០ |
| គណិតវិទ្យា | ៥៧ | ៦០ |
| រូបវិទ្យា | ២៣ | ២៨ |
| គីមីវិទ្យា | ២៦ | ២៨ |
| ជីវវិទ្យា | ៣០ | ៣០ |
| សីលធម៌-ពលរដ្ឋវិជ្ជា | ២៨ | ៣០ |
| ប្រវត្តិវិទ្យា | ៣០ | ៣០ |
| ភូមិវិទ្យា | ៣៧ | ៣៨ |
| ផែនដី និងបរិស្ថានវិទ្យា | ២៥ | ៤២ |
| ភាសាបរទេស | ៤០ | ៤២ |

| | | |
|---|---|---|
| គេហវិទ្យា | ២៤ | ២៩ |
| អប់រំកាយ កីឡា និងសុខភាព | ៤៥ | ៤៧ |
| បំណិនជីវិតតាមមូលដ្ឋាន | ៣៥ | ៣២ |
| ផលបូកពិន្ទុប្រឡងឆមាស | ៤៧២ | ៥០៥ |
| មធ្យមភាគពិន្ទុប្រឡងឆមាស | ៣១.៤៦ | ៣៣.៦៦ |
| មធ្យមភាគពិន្ទុខែប្រចាំឆមាស | ៣៥.២៤ | ៣៧.២៣ |
| មធ្យមភាគពិន្ទុប្រចាំឆមាស | ៣៣.៣៥ | ៣៥.៤៤ |

មធ្យមភាគពិន្ទុប្រចាំឆ្នាំ $= \frac{៣៣.៣៥+៣៥.៤៤}{២} =$ ៣៤.៣៩

## ៥. ការប្រឡងឆមាសសម្រាប់ថ្នាក់ទី១០ និងថ្នាក់ទី១១

ចំពោះសិស្សថ្នាក់ទី១០ និងទី១១មធ្យមភាគពិន្ទុប្រចាំឆ្នាំត្រូវគិតពិន្ទុខែជាមួយផង។ ការប្រឡងឆមាសគឺត្រូវធ្វើគ្រប់មុខវិជ្ជាដែលមានចែងក្នុងកម្មវិធីសិក្សា។

### ៥.១-រយៈពេលប្រឡង និងរបបពិន្ទុ

**ក-សម្រាប់ថ្នាក់ទី១០ ពិន្ទុសរុប=៨០០**

| ល.រ | វិញ្ញាសា | រយៈពេល (នាទី) | ពិន្ទុអតិបរមា |
|---|---|---|---|
| ១ | ភាសាខ្មែរ | ១៨០ | ១៥០ |
| ២ | គណិតវិទ្យា | ១៨០ | ១៥០ |
| ៣ | រូបវិទ្យា | ៦០ | ៥០ |
| ៤ | គីមីវិទ្យា | ៤៥ | ៣៧ |
| ៥ | ជីវវិទ្យា | ៤៥ | ៣៨ |
| ៦ | ផែនដី និងបរិស្ថានវិទ្យា | ៣០ | ២៥ |
| ៧ | ប្រវត្តិវិទ្យា | ៤៥ | ៣៧ |
| ៨ | ភូមិវិទ្យា | ៤៥ | ៣៨ |
| ៩ | សីលធម៌-ពលរដ្ឋវិជ្ជា | ៤៥ | ៣៨ |
| ១០ | គេហវិទ្យា | ៤៥ | ៣៧ |
| ១១ | ភាសាបរទេស | ១២០ | ១០០ |
| ១២ | អប់រំកាយ កីឡា និងសុខភាព | ៦០ | ៥០ |
| ១៣ | បំណិនជីវិតតាមមូលដ្ឋាន | ៦០ | ៥០ |

**ខ- សម្រាប់ថ្នាក់ទី១១ ពិន្ទុសរុប=៨២៥**

| ល.រ | វិញ្ញាសា | ថ្នាក់ៈ វិទ្យាសាស្ត្រ | | ថ្នាក់ៈ វិទ្យាសាស្ត្រសង្គម | |
|---|---|---|---|---|---|
| | | រយៈពេល(នាទី) | ពិន្ទុអតិបរមា | រយៈពេល(នាទី) | ពិន្ទុអតិបរមា |
| ១ | អក្សរសាស្ត្រខ្មែរ | ៩០ | ៧៥ | ១៥០ | ១២៥ |
| ២ | គណិតវិទ្យា | ១៥០ | ១២៥ | ៩០ | ៧៥ |
| ៣ | រូបវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |
| ៤ | គីមីវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |

| | | | | | |
|---|---|---|---|---|---|
| ៥ | ដីវិទ្យា | ៩០ | ៧៥ | ៦០ | ៥០ |
| ៦ | ផែនដី និងបរិស្ថានវិទ្យា | ៦០ | ៥០ | ៦០ | ៥០ |
| ៧ | ភូមិវិទ្យា | ៦០ | ៥០ | ៩០ | ៧៥ |
| ៨ | ប្រវត្តិវិទ្យា | ៦០ | ៥០ | ៩០ | ៧៥ |
| ៩ | សីលធម៌-ពលរដ្ឋវិជ្ជា | ៦០ | ៥០ | ៩០ | ៧៥ |
| ១០ | ភាសាបរទេស | ៦០ | ៥០ | ៦០ | ៥០ |
| ១១ | អប់រំកាយ កីឡា និងសុខភាព | ៦០ | ៥០ | ៦០ | ៥០ |
| ១២ | សេដ្ឋកិច្ច | ៦០ | ៥០ | ៦០ | ៥០ |
| ១៣ | អប់រំវិជ្ជាជីវៈជម្រើស | ៦០ | ៥០ | ៦០ | ៥០ |

### ៥.២-មធ្យមភាគពិន្ទុប្រចាំឆ្នាំ

- មធ្យមភាគពិន្ទុប្រចាំខែ=ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i=១៦ សម្រាប់ថ្នាក់ទី១០ និងចែកនឹងសន្ទស្សន៍ i = ១៦.៥ សម្រាប់ថ្នាក់ទី១១ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុខែក្នុងឆមាសចែកនឹងចំនួនខែក្នុងឆមាស(គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រឡងឆមាស = ផលបូកពិន្ទុប្រឡងឆមាសគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i = ១៦ សម្រាប់ថ្នាក់ទី១០ និងចែកនឹងសន្ទស្សន៍ i = ១៦.៥ សម្រាប់ថ្នាក់ទី១១ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆមាស= $\frac{\text{មធ្យមភាគពិន្ទុប្រឡងឆមាស+មធ្យមភាគពិន្ទុខែប្រចាំឆមាស}}{២}$ (គិត៥០ពិន្ទុ)
- មធ្យមភាគពិន្ទុប្រចាំឆ្នាំ= $\frac{\text{មធ្យមភាគពិន្ទុប្រចាំឆមាសទី១+មធ្យមភាគពិន្ទុប្រចាំឆមាសទី២}}{២}$ (គិត៥០ពិន្ទុ)

**កំណត់សម្គាល់៖**

ចំពោះគ្រឹះស្ថានមធ្យមសិក្សាណាដែលមានលទ្ធភាពបង្រៀនកម្មវិធីបំណិនជីវិតតាមមូលដ្ឋានឬកម្មវិធីអប់រំ វិជ្ជាជីវៈជម្រើសច្រើនមុខវិជ្ជាដូចជាសិល្បៈ កសិកម្ម រោងជាង កុំព្យូទ័រ...ត្រូវអនុវត្តរូបមន្ត ដើម្បីគណនាសន្ទស្សន៍ i = $\frac{\text{ផលបូកពិន្ទុគ្រប់មុខវិជ្ជា}}{៥០}$ ឯការកំណត់ឱ្យឡើងថ្នាក់ ឬប្រឡងឡើងថ្នាក់ ឬរៀនត្រួតថ្នាក់ គឺអនុវត្ត តាមប្រកាសលេខ ២៧៨៦ អយក.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ។

## ៦. ការរៀបចំប្រឡងឆមាស

### ៦.១-ការរៀបចំប្រធានវិញ្ញាសា

- គ្រូបង្រៀនតាមមុខវិជ្ជា តាមកម្រិតថ្នាក់នីមួយៗ ត្រូវទទួលខុសត្រូវទាំងស្រុងលើសុវត្ថិភាពប្រធានវិញ្ញាសាដែលខ្លួនបានរៀបចំ
- គ្រូបង្រៀនតាមមុខវិជ្ជា តាមកម្រិតថ្នាក់នីមួយៗ ត្រូវម្ចាស់ការរៀបចំប្រធានវិញ្ញាសាប្រឡងឆមាស សម្រាប់ថ្នាក់ដែលខ្លួនបានបង្រៀន
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាត្រូវប្រជុំណែនាំគ្រូបង្រៀនគ្រប់មុខវិជ្ជាប្រឡងទាំងអស់ឱ្យរៀបចំប្រធានវិញ្ញាសាឱ្យមានលក្ខណៈស្តង់ដាររួមមួយដោយយកចិត្តទុកដាក់លើ៖
  * កម្រិតប្លុមតាក់សូណូមីនៃវិញ្ញាសា៖វិញ្ញាសានីមួយៗត្រូវមានសំណួរឬលំហាត់ដែលមានកម្រិតប្លុមតាក់សូណូមីចម្រុះគ្នាពីទាបទៅខ្ពស់យ៉ាងហោចណាស់ដល់កម្រិតទី៤ក្នុងចំណោមកម្រិតទាំង៦នៃប្លុមតាក់សូណូមីគឺ៖ ១-កម្រិតចងចាំ ២-កម្រិតយល់ ៣-កម្រិតអនុវត្ត ៤-កម្រិតវិភាគ ៥-កម្រិតវាយតម្លៃ និង៦-កម្រិតបង្កើតថ្មី

* កម្រិតលំបាកនៃវិញ្ញាសា៖ វិញ្ញាសានីមួយៗត្រូវមានសំណួរឬលំហាត់ដែលមានកម្រិតលំបាកចម្រុះគ្នាពីងាយទៅលំបាក។ ឧទាហរណ៍ថាវិញ្ញាសាមួយមាន៥សំណួរ ត្រូវមានសំណួរងាយ២សំណួរ សំណួរមធ្យម២សំណួរ និងសំណួរលំបាក១សំណួរ
* ការគ្របដណ្តប់កម្មវិធីសិក្សា៖ វិញ្ញាសានីមួយៗត្រូវមានសំណួរឬលំហាត់ដែលគ្របដណ្តប់កម្មវិធីសិក្សាចាប់ ពីជំពូកមេរៀននៅដើមឆ្នាំសិក្សា កណ្តាលឆ្នាំសិក្សា និងចុងឆ្នាំសិក្សា។ គ្រូបង្រៀនតាមមុខវិជ្ជាត្រូវលែលកចេញវិញ្ញាសាមួយដែលមានខ្លឹមសារនៅច្រើនជំពូកមេរៀនដែលខ្លួនបានបង្រៀន និងសិស្សបានរៀននៅក្នុងថ្នាក់ នៅក្នុងម៉ោងតាមកាលវិភាគប្រចាំថ្នាក់ តាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗជាពិសេសត្រូវជំរុញគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗបង្រៀនឱ្យបានចប់តាមកម្មវិធីសិក្សាកំណត់របស់ក្រសួង
* ថេរវេលានិងពិន្ទុនៃវិញ្ញាសា៖ វិញ្ញាសានីមួយៗត្រូវមានពិន្ទុនិងថេរវេលាសរុបគិតជានាទីដូចចែងខាងលើ។ ដើម្បីប៉ាន់ស្មានថេរវេលានៃវិញ្ញាសានីមួយៗគេត្រូវប៉ាន់ស្មានថេរវេលានៃសំណួរឬលំហាត់នីមួយៗរួចទើបបូកសរុបថេរវេលានៃវិញ្ញាសាទាំងមូល។

- ការរៀបចំប្រធានវិញ្ញាសាការសរសេរតាមអាន ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ៥២ អយក.សណន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្រៀនសរសេរតាមអាននៅមធ្យមសិក្សាបឋមភូមិ ថ្នាក់ទី៧ ទី៨ និងទី៩ ដែលវិញ្ញាសានេះត្រូវឱ្យពិន្ទុលើអក្ខរាវិរុទ្ធ សំណួរទាក់ទងនឹងអត្ថបទ ការពន្យល់ពាក្យ ពាក្យផ្ទុយ ពាក្យសូរដូច (សទិសសូរ) ពាក្យន័យដូច (សទិសន័យ) និងវេយ្យាករណ៍
- ប្រធានវិញ្ញាសាប្រឡងឆមាសគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ទាំងអស់ ត្រូវចម្លងដាក់លើក្តារខៀន
- ការរៀបចំប្រធានវិញ្ញាសាសម្រាប់ថ្នាក់ទី៩ និងថ្នាក់ទី១២ត្រូវផ្អែកលើស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា
- សិស្សត្រូវប្រើប្រាស់ក្រដាសសៀវភៅធ្វើជាសន្លឹកប្រឡង។

## ៦.២–ការរៀបចំដំណើរការសំណេរ

- គ្រូបង្រៀនតាមមុខវិជ្ជាត្រូវគ្រប់គ្រងដំណើរការសំណេរនៅតាមថ្នាក់នីមួយៗដែលខ្លួនបានបង្រៀន
- គ្រូបង្រៀនតាមមុខវិជ្ជាអាចពឹងពាក់គ្នាទៅវិញទៅមកឱ្យជួយគ្រប់គ្រងដំណើរការសំណេរនៅតាមថ្នាក់នីមួយៗ សំដៅធ្វើឱ្យដំណើរការប្រឡងនៅគ្រប់ថ្នាក់ទាំងអស់ដែលខ្លួនបានបង្រៀនអាចដំណើរការប្រឡងក្នុងពេលវេលាតែមួយ និងមានប្រធានវិញ្ញាសារួមតែមួយដែរ។

## ៦.៣–ការរៀបចំដំណើរការកំណែ

- គ្រូបង្រៀនតាមមុខវិជ្ជាមានភារកិច្ចកែចែកសន្លឹកកិច្ចការដល់សិស្សវិញនៅពេលកែរួចនិងធ្វើកំណែប្រធានវិញ្ញាសានៅតាមថ្នាក់នីមួយៗសំដៅធ្វើឱ្យសិស្សអាចស្វែងយល់អំពីកំហុសរបស់ខ្លួននៅពេលធ្វើវិញ្ញាសានេះ
- គ្រូបង្រៀន តាមមុខវិជ្ជាមានភារកិច្ចរៀបចំតារាងស្រង់ពិន្ទុតាមថ្នាក់ដែលខ្លួនបានបង្រៀនដើម្បីប្រគល់ជូនទីចាត់ការសាលាឱ្យបានទាន់ពេលវេលាកំណត់។

**កំណត់សម្គាល់៖**

- ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សាក្រោយពេលដំណើរការសំណេរនៃការប្រឡងគ្រូបង្រៀនទាំងអស់ត្រូវបន្តបង្រៀនជាធម្មតាតាមកាលវិភាគកំណត់
- នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សា មិនត្រូវបិទសាលារៀនដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡានោះទេ

– ការប្រឡងឆមាសសម្រាប់ថ្នាក់ទី១០ទី១១ និងទី១២ ចំពោះមុខវិជ្ជាគណិតវិទ្យា និងភាសាខ្មែរ ឬអក្សរសាស្ត្រខ្មែរ មានរយៈពេលប្រឡងវែងលើសពីម៉ោងរបស់គ្រូបង្រៀនមានតាមថ្នាក់នីមួយៗ។ ក្នុងករណីនេះនាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាត្រូវអនុញ្ញាតឱ្យគ្រូបង្រៀនមុខវិជ្ជាទាំងពីរនេះខ្វះម៉ោង ឬគ្រូបង្រៀនមុខវិជ្ជាផ្សេងទៀតត្រូវជួយគ្រប់គ្រងដំណើរការសំណេរសម្រាប់ការប្រឡងមុខវិជ្ជាទាំងពីរនេះ។

**៦.៤–ការបិទផ្សាយពិន្ទុ**

មធ្យមភាគពិន្ទុប្រចាំខែ មធ្យមភាគពិន្ទុខែប្រចាំឆមាស មធ្យមភាគពិន្ទុប្រឡងឆមាស មធ្យមភាគពិន្ទុប្រចាំឆមាស មធ្យមភាគពិន្ទុប្រចាំឆ្នាំ ដាច់ខាតត្រូវបិទផ្សាយនៅតាមបន្ទប់រៀន ១ច្បាប់ និងនៅទីចាត់ការ ១ច្បាប់។ នាយក នាយិកាសាលាត្រូវទទួលខុសត្រូវក្នុងការបិទផ្សាយពិន្ទុសិស្ស និងជានាតម្លាភាព។

**៦.៥–ការលុបបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សា**

ចំពោះសិស្សថ្នាក់ទី៩ និងទី១២ នៃគ្រឹះស្ថានមធ្យមសិក្សាណាមួយ អវត្តមានមួយ ឬពីរមុខវិជ្ជាដោយមានការសុំច្បាប់ និងមានមូលហេតុច្បាស់លាស់នៅពេលប្រឡងឆមាសជាស្វ័យប្រវត្តិសិស្សនោះត្រូវបានពិន្ទុមុខវិជ្ជានោះស្មើនឹងពិន្ទុទាបជាងគេរបស់សិស្សដែលបានប្រឡងឆមាសក្នុងសាលារៀននោះ។ ក្នុងករណីនេះនាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សា និងគ្រូទទួលបន្ទុកថ្នាក់ត្រូវធ្វើការប្រជុំសម្រេចហើយធ្វើកំណត់ហេតុដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ផ្សេងៗ ( សំបុត្រពេទ្យ ... ។ល។ )។

ការលុបបេក្ខភាព ត្រូវធ្វើដោយយកចិត្តទុកដាក់ និងហ្មត់ចត់ មានន័យថាសិស្សដែលត្រូវលុបបេក្ខភាពត្រូវផ្អែកលើករណីបីយ៉ាងដូចតទៅ៖

*__ករណីទី១៖__ សិស្សមានមធ្យមភាគពិន្ទុប្រចាំឆ្នាំក្រោម ២៥,០០

*__ករណីទី២៖__ សិស្សគ្មានមធ្យមភាគពិន្ទុប្រឡងឆមាស ៖

– ឈប់ឥតច្បាប់ក្នុងពេលប្រឡងឆមាសមុខវិជ្ជាណាមួយ
– ឈប់មានច្បាប់ក្នុងពេលប្រឡងឆមាសចាប់ពី បីមុខវិជ្ជាឡើងទៅ។

*__ករណីទី៣៖__ សិស្សអវត្តមានក្នុងឆ្នាំសិក្សាលើសពីចំនួនកំណត់ ៖

– អវត្តមានឥតច្បាប់លើសពី ៣០ ដងឡើងទៅ
– អវត្តមានឥតច្បាប់ និងមានច្បាប់លើសពី ៤០ ដងឡើងទៅ
– អវត្តមានមានច្បាប់លើសពី ៥៥ ដងឡើងទៅ។

** ការលុបបេក្ខភាពត្រូវធ្វើបញ្ជីច្បាស់លាស់ និងតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាចៀសវាងការច្រឡំលុបខុសឈ្មោះ ឬយឺតយ៉ាវក្នុងការធ្វើបញ្ជីលុបឈ្មោះ នាំឱ្យមានបញ្ហាពិបាកដោះស្រាយ។

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងទទួលខុសត្រូវចំពោះមុខក្រសួងក្នុងការលុបបេក្ខភាពនេះ។**

**កំណត់សម្គាល់៖**

* មុខវិជ្ជាភាសាបរទេសសិស្សត្រូវជ្រើសរើសយកភាសាតែមួយប៉ុណ្ណោះក្នុងចំណោមភាសាបារាំងនិងអង់គ្លេស។ ចំពោះសិស្សថ្នាក់ទី៩ និងទី១២ ដែលបានជ្រើសរើសយកភាសាណាមួយនៅពេលប្រឡងឆមាស ត្រូវបន្តជ្រើសរើសយកភាសាដដែលសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សា

* ចំពោះសិស្សថ្នាក់ទី១២ ដែលបានជ្រើសរើសថ្នាក់៖ វិទ្យាសាស្ត្រ ឬថ្នាក់៖ វិទ្យាសាស្ត្រសង្គម ដើម្បីសិក្សាតាំងពីដើមឆ្នាំសិក្សាមកហើយនៅពេលប្រឡងឆមាសត្រូវបន្តជ្រើសរើសយកថ្នាក់៖ វិទ្យាសាស្ត្រ ឬថ្នាក់៖ វិទ្យាសាស្ត្រសង្គមដដែលសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ពោលគឺពុំអនុញ្ញាតឱ្យប្ដូរទេ

* អវត្តមានគិតត្រឹមថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣ ចំពោះសិស្សថ្នាក់ទី៩ និងទី១២។

## ៧. ការប្រគល់តារាងស្រង់ពិន្ទុប្រឡងឆមាស មកមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និង នាយកដ្ឋានកិច្ចការប្រឡង នៃក្រសួងអប់រំ យុវជន និងកីឡា

នាយក នាយិកាគ្រឹះស្ថានមធ្យមសិក្សាទាំងអស់ត្រូវធ្វើតារាងស្រង់ពិន្ទុប្រឡងឆមាសតាមកាលបរិច្ឆេទដូចខាងក្រោម៖

* **ឆមាសទី១ ៖**

- សម្រាប់ថ្នាក់ទី៩ ត្រូវប្រគល់តារាងស្រង់ពិន្ទុ មកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមីឱ្យបានមុន **ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣** ហើយមន្ទីររៀបចំស្ថិតិរួមត្រូវប្រគល់មកនាយកដ្ឋានកិច្ចការប្រឡង ឱ្យបានមុន**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣** ជាកំហិត
- សម្រាប់ថ្នាក់ទី១២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវប្រគល់តារាងស្រង់ពិន្ទុមកនាយកដ្ឋានកិច្ចការប្រឡង ឱ្យបានមុន**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣** ជាកំហិត។

* **ឆមាសទី២ និងប្រចាំឆ្នាំ ៖**

- សម្រាប់ថ្នាក់ទី៩ ត្រូវប្រគល់តារាងស្រង់ពិន្ទុ មកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមីឱ្យបានមុន **ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣** ហើយមន្ទីររៀបចំស្ថិតិរួមប្រគល់មកនាយកដ្ឋានកិច្ចការប្រឡងឱ្យបានមុន**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣** ជាកំហិត
- សម្រាប់ថ្នាក់ទី១២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវប្រគល់តារាងស្រង់ពិន្ទុ មកនាយកដ្ឋានកិច្ចការប្រឡង ឱ្យបានមុន **ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣** ជាកំហិត។

សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាត់តាំងអនុវត្តសេចក្តីណែនាំនេះឱ្យទទួលបានលទ្ធផលល្អ និងប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានកិច្ចការប្រឡង